00636138

E6

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ~~002/13-01-2011/អ.វ.ត.ក/អជសដ~~ 002/19-09-2007-អវតក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន: ~~សម្ងាត់ / Confidential / Confidentiel~~ សាធារណៈ /Public

ឈ្មោះមន្ត្រីកត់ត្រា: [signature] ៣១-មករា-២០១១

ហត្ថលេខា:

---

**សំណើសុំអោយបំពេញកិច្ចស៊ើបសួរទាក់ទងនឹងបណ្តឹងរបស់លោក អៀង សារី សុំប្តឹងជំទាស់ចៅក្រម និល ណុន ដោយសារគេយល់ឃើញថាគាត់បានទទួលស្គាល់ថា គាត់បានទទួលយកសំណូក ដោយស្នើសុំ ឬចេញដីកាបង្គាប់អោយអ្នកផលិតភាពយន្ត AMANDA PIKE អោយលាតត្រដាងបង្ហាញខ្សែភាពយន្តនៃកិច្ចសម្ភាសន៍របស់គាត់ជាមួយចៅក្រម និល ណុន និងលិខិតអនុញ្ញាតឲ្យចាក់ផ្សាយដែលមានហត្ថលេខារបស់លោក និល ណុន**

---

<u>ដាក់ដោយ៖</u>

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

<u>ផ្ញើជូន៖</u>

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERNGE

ចៅក្រម យូ ឧត្តរា

ចៅក្រម Claudia FENZ

<u>ផ្ញើជូន៖</u>

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ឯកសារទទួល**

**DOCUMENT RECEIVED/DOCUMENT REÇU**

ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 14 / 01 / 2011

ម៉ោង (Time/Heure): 11:30

មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) ដោយអនុលោមទៅតាមវិធាន ៤១ និង ៩៣ នៃវិធានផ្ទៃក្នុងរបស់ អវតក (“វិធាន”) សូមដាក់សំណើសុំអោយបំពេញកិច្ចស៊ើបសួរទាក់ទងនឹងបណ្តឹងរបស់លោក អៀង សារី សុំប្តឹងជិតចិត្តចៅក្រម និល ណុន ដោយសារគេយល់ឃើញថាគាត់បានទទួលស្គាល់ថា គាត់បានទទួលយកសំណូក ដោយស្នើសុំ ឬចេញដីកាបង្គាប់អោយអ្នកផលិតភាពយន្ត Amanda Pike អោយលាតត្រដាងបង្ហាញខ្សែភាពយន្តនៃកិច្ចសម្ភាសន៍របស់គាត់ជាមួយចៅក្រម និល ណុន និងលិខិតអនុញ្ញាតឲ្យចាក់ផ្សាយដែលមានហត្ថលេខារបស់លោក និល ណុន ។ ដោយធ្វើព្រមគ្នាជាមួយនឹង ហើយដែលទាក់ទងនឹងសំណើសុំនេះ មេធាវីការពារក្តីបានដាក់ពាក្យបណ្តឹងរបស់ លោក អៀង សារី សុំប្តឹងជិតចិត្តចៅក្រម និល ណុន ដោយសារគេយល់ឃើញថាគាត់បានទទួលស្គាល់ថា គាត់បានទទួលយកសំណូក និងសំណើសុំអោយមានសវនាការជាសាធារណៈ ឬជម្រើសផ្សេងពីនេះអនុញ្ញាតអោយដាក់ចម្លើយតបទៅនឹងអំណះអំណាងនានាដាក់ដោយចៅក្រម និល ណុន ជាកិច្ចឆ្លើយតបទៅនឹងពាក្យបណ្តឹងនេះ (“ពាក្យបណ្តឹងជិតចិត្ត”)[1]។ បណ្តឹងនេះត្រូវធ្វើឡើងជាចាំបាច់ដោយហេតុថា អ្នកផលិតខ្សែភាពយន្ត Amanda Pike បានរាយការណ៍ថា ចៅក្រម និល ណុន ក្នុងអំឡុងពេលសម្ភាសន៍ដែលមានថតជារូបភាពវីដេអូនោះ បានឆ្លើយទទួលស្គាល់ថាបានទទួលយកសំណូក ខណៈពេលដែលចៅក្រម និល ណុន ត្រូវបានគេរាយការណ៍ថា បានបដិសេធថាមិនដែលបានឆ្លើយទទួលស្គាល់បែបនេះ ឬសូម្បីតែថាបានជួបសម្ភាសន៍ជាមួយអ្នកនាង Pike។ ខណៈពេលដែល “ចំណុចចាប់ផ្តើមសម្រាប់ធ្វើការកំណត់សម្រេចអំពីការចោទប្រកាន់ពីភាពលំអៀង គឺជាការសន្មតទុកជាមុន អំពីភាពអនាគតិ ដែលមានចំពោះចៅក្រមអង្គជំនុំជម្រះវិសាមញ្ញ ដែលបានផ្អែកលើការធ្វើសច្ចាប្រណិធានចូលកាន់ដំណែងរបស់ចៅក្រម និងលក្ខណៈសម្បត្តិនានាសម្រាប់ការតែងតាំងពួកគាត់”[2] ក្រោយពីពេលមានអត្ថបទសរសេរជាសាធារណៈ ដែលក្នុងនោះបានបង្ហាញថាចៅក្រម និល ណុន បានឆ្លើយទទួលស្គាល់ថាបានទទួលយកសំណូក (សារគុណជាប្រាក់កាសបានមកពីភាគីវិវាទដែលបានដឹងគុណ) ចៅក្រម និល ណុន អាចមិនត្រូវបានការ

---

[1] *រឿងក្តី* អៀង សារី សំណុំរឿងលេខ ០០២/១៣-០១-២០១១-អវតក/អជសង ពាក្យបណ្តឹងរបស់ លោក អៀង សារី សុំប្តឹងជិតចិត្តចៅក្រម និល ណុន ដោយសារគេយល់ឃើញថាគាត់បានទទួលស្គាល់ថា គាត់បានទទួលយកសំណូក និងសំណើសុំអោយមានសវនាការជាសាធារណៈ ឬជម្រើសផ្សេងពីនេះអនុញ្ញាតអោយដាក់ចម្លើយតបទៅនឹងអំណះអំណាងនានាដាក់ដោយចៅក្រម និល ណុន ជាកិច្ចឆ្លើយតបទៅនឹងពាក្យបណ្តឹងនេះ ចុះថ្ងៃទី ១៤ មករា ២០១១។

[2] *សូមមើលរឿងក្តី* អៀង សារី សំណុំរឿងលេខ ០០២/២០-១០-២០០៩-អវតក/អបជ(០៣) សេចក្តីសម្រេចទៅលើសំណើរបស់ជនត្រូវចោទ អៀង សារី សុំអោយមានវិធានការសមរម្យពាក់ព័ន្ធទៅនឹងសេចក្តីថ្លែងការណ៍មួយចំនួនដែលធ្វើដោយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានគតាំងនឹងឯករាជ្យភាពរបស់ចៅក្រមអង្គបុរេជំនុំជម្រះចៅក្រម Katinka Lahuis និងចៅក្រម Rowan Downing ចុះថ្ងៃទី ៣០ វិច្ឆិកា ២០០៩ ឯកសារលេខ 5, ERN: 00404595-00404601 កថាខណ្ឌ ៦។

ពារដោយការសន្មតទុកជាមុន អំពីភាពអនាគតិបានទៀតឡើយ។ តាមពិត សូមស្នើថា ភស្តុតាង*តាមការពិនិត្យជាបឋម (prima facie)* មានអត្ថិភាពដែលផ្ទុយពីនេះ ដែលនោះគឺជាពាក្យបណ្តឹងជំទាស់។ ចាប់តាំងពីអ្នកនាង Pike បដិសេធមិនប្រគល់ដោយស្ម័គ្រចិត្តនូវខ្សែភាពយន្តនេះមកមេធាវីការពារក្តី វាជាប្រយោជន៍នៃយុត្តិធម៌ដែលថាសំណើសុំត្រូវធ្វើឡើង ឬដីកាបង្គាប់ត្រូវចេញដោយអង្គជំនុំជម្រះសាលាដំបូងដោយបង្ខំអោយអ្នកនាង Pike ប្រគល់មកអោយនូវខ្សែវីដេអូនៃកិច្ចសម្ភាសន៍រវាងអ្នកនាង Pike ជាមួយនឹងចៅក្រម និល ណុន និងលិខិតអនុញ្ញាតអោយចាក់ផ្សាយដែលចុះហត្ថលេខាដោយចៅក្រម និល ណុន។ បើសិនជាមានការចាំបាច់ដើម្បីស្តាប់យកចម្លើយពីអ្នកនាង Pike អង្គជំនុំជម្រះសាលាដំបូងគួរចេញដីកាបង្គាប់អោយអ្នកនាង Pike ចូលមកបង្ហាញខ្លួននៅចំពោះមុខ អវតក ។

## I. សាវតា

១. ក្នុងឆ្នាំ ២០០២ អ្នកថតភាពយន្តឯកសារ Amanda Pike បានធ្វើដំណើរមកដល់កម្ពុជាក្នុងគម្រោងការយកព័ត៌មានអន្តរជាតិ (International Reporting Project Fellowship) ដែលទទួលបានមកពីសកលវិទ្យាល័យ Johns Hopkins (Paul H. Nitze School of Advanced International Studies of Johns Hopkins University)[3] ហើយបានផលិតភាពយន្តឯកសារមួយក្រោមចំណងជើងថា "កម្ពុជា៖ ស្រមោលរបស់ ប៉ុល ពត" (Cambodia: Pol Pot's Shadow) ។

២. ខណៈពេលថតខ្សែភាពយន្តឯកសារនេះ អ្នកនាង Pike ក៏បានធ្វើការស្រាវជ្រាវរឿងផ្សេងទៀត ដែលក្រោយមកបង្កើតបានជា អត្ថបទសរសេរជាច្រើនដែលជាផ្នែកមួយនៃទិន្នានុលេខ (Dirary) ជាបន្តបន្ទាប់ ហើយបានដាក់បង្ហោះផ្សាយលើអាំងទែណេតនៃគេហទំព័ររបស់ Frontline/World ដែលគេនៅតែអាចរកឃើញអត្ថបទទាំងនេះរហូតដល់សព្វថ្ងៃនេះ[4]។ ក្នុងចំណោមអ្នកដែលត្រូវបានគាត់សម្ភាសន៍មានចៅក្រម និល ណុន ដែលកាលនោះជាប្រធានតុលាការខេត្តបាត់ដំបង។ ការសម្ភាសន៍នេះបានក្លាយជាអត្ថបទសរសេររបស់គាត់ដែលមានចំណងជើងថា "ខេត្តបាត់ដំបង៖ ចៅក្រម" (Battambang: The Judge)។ នៅក្នុងអត្ថបទសរសេរនេះ អ្នកនាង Pike បានរាយការណ៍ថា៖

---

[3] *សូមមើល* គេហទំព័រ http://www.internationalreportingproject.org/stories/detail/665/.។

[4] *សូមមើល* គេហទំព័រ http://www.pbs.org/frontlineworld/stories/cambodia/diary01a.html.។

យើងជជែកជាមួយចៅក្រម និល ដែលគាត់និយាយថា គាត់ពិបាកចិត្តដោយសារប្រជាជនខ្លះជំនឿជឿជាក់នៅក្នុងប្រព័ន្ធយុត្តិធម៌។ គាត់បានត្អូញត្អែរថា គាត់ជាញឹកញាប់ត្រូវតែការពារវិជ្ជាជីវៈ និងមិត្តភក្តិរបស់គាត់។ ក្រៅពីនោះ គាត់ទទួលបានប្រាក់ខែត្រឹមតែ ៣០ដុល្លាប៉ុណ្ណោះក្នុងមួយខែ ដែលស្ទើតែមិនគ្រាន់សម្រាប់ចិញ្ចឹមគ្រួសាររបស់គាត់។ គាត់សួរដោយញញឹមចេញធ្មេញថា តើមានអ្វីទៀតដែលគាត់គួរធ្វើនោះ?[5]

៣. ក្នុងខែ មិថុនា ២០០៦ ចៅក្រម និល ណុន ត្រូវបានគេរាយការណ៍ថាបានបដិសេធថា គាត់មិនដែលបាននិយាយទទួលស្គាល់បែបនេះទេ ឬធ្លាប់ចូលរួមការសម្ភាសន៍បែបនេះជាមួយអ្នកនាង Pike ឡើយ[6]។ នាចុងខែដដែលនោះ ចៅក្រម និល ណុន ត្រូវបានអ្នកយកព័ត៌មានរបស់កាសែត ខឹមបូឌៀដេលី (The Cambodia Daily) គឺ James Welsh (ដែលសព្វថ្ងៃគឺជាពណ្ណាធិការ ឬអ្នកចាត់ចែងបោះពុម្ពផ្សាយ (Managing Editor)) និង Prak Chan Tul បានទំនាក់ទំនងមកចៅក្រម និល ណុន ដើម្បីមានមតិអំពីអ្វីដែលបានរាយការណ៍ដោយអ្នកនាង Pike ឧទាហរណ៍ដូចជាថា ចៅក្រម និល ណុន បានទទួលស្គាល់ការទទួលយកប្រាក់កាសពីភាគីវិវាទដែលពេញចិត្តពេញថ្លើមនឹងសេចក្តីសម្រេចរបស់គាត់។ ចៅក្រម និល ណុន បានឆ្លើយតប បើតាមអត្ថបទសរសេររបស់កាសែត ខឹមបូឌៀដេលី ដែលមានចំណងជើងថា "អ្នកផលិតខ្សែថតភាពយន្តបានអោយដឹងថា ចៅក្រមនៅ អវតក បានទទួលយកប្រាក់ពីប្រជាជន" ចុះផ្សាយថ្ងៃទី ១០ និង ១១ មិថុនា ២០០៦ ថា "ខ្ញុំមិនដឹង។ ខ្ញុំមិនផ្តល់ព័ត៌អ្វីទេ"។ អត្ថបទសរសេរនេះបាននិយាយបន្ថែមថា ៖

> អ្នកនាង Amanda Pike អ្នកផលិតខ្សែភាពយន្តឯកសារដែលមានចំណងជើងថា "កម្ពុជា: ស្រមោលរបស់ប៉ុលពត" បានសរសេរក្នុងសារអេឡិចត្រូនិចមួយដែលបានទទួលកាលពីថ្ងៃសុក្រថា នាងបានពិនិត្យឡើងវិញយ៉ាងយកចិត្តទុកដាក់នូវខ្សែអាត់សម្លេង និងអត្ថបទចម្លងជាលាយល័ក្ខណអក្សរអំពីបទសម្ភាសន៍ជាមួយលោក និល ណុន។
>
> អ្នកនាងបានបន្ថែមទៀតថា៖ "យើងបានសម្ភាសន៍ចៅក្រម និល ណុន ដោយមានការថតរូបភាពវីដេអូ អស់រយៈពេល១ម៉ោង និង៤៥នាទី កាលពីថ្ងៃទី២១ ខែមិនា ឆ្នាំ២០០២

[5] *សូមមើល* Amanda Pike *កម្ពុជា៖ស្រមោលរបស់ប៉ុលពត (Cambodia: Pol Pot's Shadow)* FRONTLINE/WORLD ខែតុលា ២០០២ *ដែលអាចរកបាននៅគេហទំព័រ* http://www.pbs.org/frontlineworld/stories/cambodia/diary04.html (គូសបញ្ជាក់បន្ថែម)។

[6] អត្ថបទសរសេររបស់ James Welsh & Prak Chan Thul ក្រោមចំណងជើងថា *អ្នកផលិតខ្សែភាពយន្តបានឱ្យដឹងថា ចៅក្រមនៅ អវតក បានទទួលប្រាក់ពីប្រជាជន* CAMBODIA DAILY ១០-១១ មិថុនា ២០០៦។

នៅក្នុងទីក្រុងភ្នំពេញ។ យើងបានថតជាខ្សែភាពយន្តនូវពិធីក្នុងបន្ទប់តុលាការខេត្តបាត់ដំបងរបស់គាត់នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០០២"។

អ្នកនាងPike បានឱ្យដឹងទៀតថា៖ "យើងក៏មានលិខិតអនុញ្ញាតឱ្យចាក់ផ្សាយដែលមានហត្ថលេខារបស់លោក និល ណុន ផងដែរដែលក្នុងនោះលោក និល ណុន យល់ព្រមឱ្យយើងថតទុកជាខ្សែភាពយន្តឯកសាររបស់យើង"។

**Pike បានបន្តទៀតថា ក្នុងអំឡុងបទសម្ភាសន៍នោះ អ្នកនាងបានសួរ លោក និល ណុន ថាតើប្រជាជន ធ្លាប់បានឱ្យប្រាក់គាត់ដើម្បីឱ្យគាត់ប្រឹងប្រែងធ្វើឱ្យពួកគេឈ្នះក្តីដែរឬទេ[sic]។**

**"លោក និល ណុន ឆ្លើយថា បាទធ្លាប់។ ករណីនេះ វាកើតឡើងចំពោះរូបខ្ញុំក៏ដូចជាអ្នកដទៃដែរ ប៉ុន្តែវាមិនមែនតាមរយៈការខិតខំប្រឹងប្រែងខាងខ្ញុំទេ។ ប៉ុន្តែប្រសិនបើបន្ទាប់ពីការជំនុំជម្រះក្តីរួច ប្រជាជនគេដឹងគុណខ្ញុំហើយពួកគេឱ្យខ្ញុំនូវអ្វីមួយវាការតបស្នងនោះ វាជារឿងធម្មតាទេ។ ខ្ញុំមិនបដិសេធឡើយ"។**

Pike បានអះអាងថា លោក និល ណុន បានបន្ថែមទៀតថា៖"ខ្ញុំបានដោះស្រាយរឿងក្តីឱ្យពួកគេ ហើយប្រជាជនគេដឹងគុណខ្ញុំ។ស្ថានភាពរស់នៅបច្ចុប្បន្ននេះមានការលំបាកសម្រាប់រូបខ្ញុំ។ ប៉ុន្តែបើអ្នកនិយាយអំពីការដាក់សំពាធលើប្រជាជនដើម្បីទទួលបានប្រាក់សំណូកវិញនោះ គឺគ្មានទេ"[7]។

៤. ដោយបានដឹងពីអត្ថបទសរសេរនេះ មេធាវីការពារក្តីបានចាត់វិធានការដើម្បីស្វែងរកអ្នកនាង Pike និងដើម្បីទទួលបាននូវខ្សែវីដេអូនៃការសម្ភាសន៍របស់អ្នកនាង Pike ជាមួយចៅក្រម និល ណុន និងលិខិតអនុញ្ញាតថត និងចាក់ផ្សាយរបស់ចៅក្រម និល ណុន[8]។ នៅថ្ងៃទី ៨ កញ្ញា ២០១០ អ្នកនាង Pike បានឆ្លើយតបតាមរយៈសារអ៊ីមែល កត់សម្គាល់ថាខ្លួនអ្នកនាង និងដៃគូរផលិតខ្សែភាពយន្តម្នាក់ទៀតលោក Adam Keker គឺជាម្ចាស់កម្មសិទ្ធិនៃសម្ភារៈវត្ថុដែលបានស្នើសុំ ហើយដោយសារ "ហេតុផលវិជ្ជាជីវៈសារព័ត៌មាន" ពួកគាត់មិនអាចផ្តល់ជូនដោយ "ស្ម័គ្រចិត្ត" នូវសម្ភារៈវត្ថុដែលបានស្នើសុំឡើយ ហើយការទំនាក់ទំនងផ្សេងៗនាអនាគតអំពីបញ្ហានេះ គួរត្រូវទំនាក់ទំនងទៅកាន់មេធាវីរបស់ពួកគេ John Keker[9]។

៥. នៅថ្ងៃទី ៩ កញ្ញា ២០១០ មេធាវីការពារក្តីបានប្រគល់លិខិតដោយផ្ទាល់ដៃទៅអ្នកចាត់ចែងបោះ

---

[7] *ដូចយោងខាងលើ*។(គូសបញ្ជាក់បន្ថែម)។

[8] *សូមមើល* ពាក្យបណ្តឹងជិតចិត្ត ឧបសម្ព័ន្ធ ក។

[9] *សូមមើល* ពាក្យបណ្តឹងជិតចិត្ត ឧបសម្ព័ន្ធ ខ។

ពុម្ពផ្សាយលោក Welsh នៅស្នាក់ការកាសែតឌីខេមបូឌៀដេលី[10]។ តាមរយៈលិខិតនេះ មេធាវីការពារក្តីបានស្នើសុំសំណៅចម្លងនៃសារអ៊ីមែលឆ្លងឆ្លើយរវាងអ្នកនាង Pike និងកាសែតឌីខេមបូឌៀដេលី ទាក់ទងនឹងការសម្ភាសន៍ជាមួយចៅក្រម និល ណុន ។ កាលពីថ្ងៃទី ១៦ កញ្ញា ២០១០ មេធាវីការពារក្តីបានទទួលលិខិតដែលផ្ញើរតាមសារអ៊ីមែល ពីលោក Welsh ដែលក្នុងនោះគាត់បានថ្លែងថា កាតព្វកិច្ចវិជ្ជាជីវៈ និងក្រមសីលធម៌របស់គាត់ បានរារាំងគាត់មិនអោយផ្តល់ដល់មេធាវីការពារក្តី នូវសំណៅចម្លងនៃសារអ៊ីមែលឆ្លងឆ្លើយរបស់គាត់បានឡើយ[11]។

## II. ច្បាប់ដែលត្រូវយកមកអនុវត្ត

៦. វិធាន ៤១ ចែងថា៖

១. <u>ដីកាកោះគឺជាការបង្គាប់ដល់បុគ្គលណាម្នាក់ ឱ្យចូលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ</u>។ ដីកានេះអាចអនុវត្តចំពោះជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី ហើយត្រូវមានចុះនិទ្ទេសរបស់បុគ្គលដែលត្រូវកោះហៅនោះផង។

២. លើកលែងតែករណីដែលមានចែងផ្សេងពីនេះនៅក្នុងវិធានផ្ទៃក្នុង រយៈពេលអប្បរមារវាងការប្រគល់ដីកានេះ និងថ្ងៃកំណត់ឱ្យចូលមកបង្ហាញខ្លួននៅចំពោះអង្គជំនុំជម្រះវិសាមញ្ញត្រូវមានរយៈពេល ៥ (ប្រាំ)ថ្ងៃ ។ ប៉ុន្តែនៅពេលដែលដីកានេះធ្វើឡើងសម្រាប់ជនជាប់ឃុំនោះ ឬ នៅពេលដែលអ្នកស៊ើបអង្កេត ឬ សហចៅក្រមស៊ើបអង្កេតស្តាប់ចម្លើយសាក្សីដោយចុះទៅដល់ទីកន្លែង ឬក្នុងកាលៈទេសៈពិសេស ពេលវេលាកំណត់នេះមិនត្រូវអនុវត្តឡើយ។

៣. ដីកាកោះទាំងអស់ ត្រូវបញ្ជូនតាមអាស័យដ្ឋានចុងក្រោយបង្អស់ដោយក្រឡាបញ្ជីនគរបាលយុត្តិធម៌ ឬមន្ត្រីដែលត្រូវបានអនុញ្ញាតដោយអង្គជំនុំជម្រះវិសាមញ្ញ តាមមធ្យោបាយណាមួយសមស្រប ។ ជនជាប់ឃុំត្រូវបានកោះហៅតាមរយៈប្រធានមន្ទីរឃុំឃាំង ។ ការបញ្ជូនដីកាបង្គាប់ឱ្យចូលខ្លួន ត្រូវសរសេរចូលក្នុងរបាយការណ៍ដោយបញ្ជាក់អំពីមធ្យោបាយបង្គាប់ឱ្យចូលខ្លួន កាលបរិច្ឆេទ ពេលវេលា និង ទីកន្លែងរួមទាំងកាលៈទេសៈ ពាក់ព័ន្ធដទៃទៀត ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីដែលបំពេញកិច្ចការនោះ និង ដាក់ចូលក្នុងសំណុំរឿង។

៤. បុគ្គលដែលទទួលភារៈជាអ្នកប្រគល់ដីកាទៅឱ្យជនណាម្នាក់ ត្រូវអនុវត្តទៅ

---

[10] *សូមមើល* ពាក្យបណ្តឹងជិតចិត្ត ឧបសម្ព័ន្ធ គ។

[11] *សូមមើល* ពាក្យបណ្តឹងជិតចិត្ត ឧបសម្ព័ន្ធ ឃ។

តាមភារកិច្ចរបស់ខ្លួន និងខិតខំឲ្យអស់ពីលទ្ធភាពដើម្បីប្រគល់ដីកា និង ទទួលបានមកវិញនូវសេចក្ដីបញ្ជាក់ទទួលស្គាល់ថាបានទទួលដីកា ។ សេចក្ដីបញ្ជាក់ទទួលស្គាល់ថាបានទទួលដីកានេះ ត្រូវដាក់ភ្ជាប់ទៅនឹងរបាយការណ៍នៃការបំពេញកិច្ចការ[12]។

៧. វិធាន ៩៣ ចែងថា៖

១. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការស៊ើបសួរថ្មីជាការចាំបាច់ អង្គជំនុំជម្រះសាលាដំបូង អាចបង្គាប់ឲ្យធ្វើការស៊ើបសួរបន្ថែមបានគ្រប់ពេលវេលា ។ សាលក្រមមុនអង្គសេចក្ដីនេះ ត្រូវកំណត់បង្ហាញអំពី ចៅក្រមមួយរូប ឬច្រើនរូប ដែលត្រូវជាអ្នកដឹកនាំការស៊ើបសួរថ្មីនេះ។

២. ចៅក្រមដែលទទួលបន្ទុកស៊ើបសួរបន្ថែម ក៏ត្រូវស្ថិតនៅក្រោមល័ក្ខខ័ណ្ឌដូចគ្នាទៅនឹងសហចៅក្រមស៊ើបអង្កេតដែរ ហើយអាច ៖

ក-ចុះទៅដល់ទីកន្លែងណាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ច នៃយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ។

ខ-ស្ដាប់ចម្លើយសាក្សី ។

គ-ដឹកនាំការឆែកឆេរ ។

ឃ-ចាប់យកវត្ថុតាង ឬ

ង-បង្គាប់ឲ្យធ្វើកោសលវិច័យ។

៣. ដើម្បីអនុវត្តការស៊ើបសួរបន្ថែមនេះ ចៅក្រមអាចចេញដីកាចាត់ឲ្យស្នួរជំនួសទៅមន្ត្រីនគរបាលយុត្តិធម៌បានដែរ[13]។

## III. សំណើសុំ

៨. មេធាវីការពារក្ដី ស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូង ដើម្បីទទួលបាននូវ៖ ១) ខ្សែភាពយន្តនៃកិច្ចសម្ភាសន៍រវាងចៅក្រម និល ណុន និងអ្នកនាង Pike ដែលជាភស្តុតាងប្រសើរបំផុតសម្រាប់បង្ហាញថា តើការសម្ភាសន៍បានធ្វើឡើងដែរឬទេ និងថា តើចៅក្រម និល ណុន បានឆ្លើយទទួលស្គាល់ដាក់បន្ទុកថាបានទទួលសំណូក ដូចដែលគេបានរាយការណ៍ដែរឬទេ។ ២) លិខិតអនុញ្ញាតអោយចាក់ផ្សាយដែលចុះហត្ថលេខាដោយចៅក្រម និល ណុន ដែលលិខិតបង្ហាញថាគាត់បាន

[12]គួសបញ្ជាក់បន្ថែម។

[13] គួសបញ្ជាក់បន្ថែម។

អនុញ្ញាតអោយថតភាពយន្ត និងសម្ភាសន៍ដោយអ្នកនាង Pike ។ មេធាវីការពារក្តី ស្នើសុំបន្ថែមថា បើសិនជាគេយល់ឃើញថាមានការចាំបាច់ អង្គជំនុំជម្រះសាលាដំបូង គួរចេញដីកាបង្គាប់អោយអ្នកនាង Pike អោយចូលមកបង្ហាញខ្លួននៅចំពោះមុខ អវតក និងផ្តល់ភស្តុតាង។

៩. មេធាវីការពារក្តី ទទួលស្គាល់ថា ខ្លួនមានបន្ទុកបង្ហាញភស្តុតាងគាំទ្រពាក្យបណ្តឹងជិតចិត្តរបស់ខ្លួន។ វិធាន ៣៤(៣) ចែងថា "ភាគីដែលធ្វើបណ្តឹងជិតចិត្ត ត្រូវបង្ហាញឲ្យច្បាស់លាស់អំពីមូលហេតុនៃបណ្តឹង និង ត្រូវមានភស្តុតាងបញ្ជាក់ផងដែរ។" អនុលោមទៅតាមនេះ អង្គបុរេជំនុំជម្រះ បានយល់ឃើញថា "ការស្វែងរកភស្តុតាង គឺជាបន្ទុករបស់អ្នកបណ្តឹងទាំងស្រុង"។ ភាពអនាគតិរបស់ចៅក្រម ត្រូវបានសន្មតទុកជាមុន លើកលែងតែមានការបង្ហាញភស្តុតាងផ្ទុយពីនេះ។ ដើម្បីដកចេញនូវការសន្មតទុកជាមុននេះ ត្រូវតែបានលើកហេតុផលនៅពេលដាក់បណ្តឹង"[14]។ ប៉ុន្តែ មេធាវីការពារក្តី បានចាត់គ្រប់វិធានការណ៍សព្វបែបយ៉ាងទៅតាមអំណាចដែលខ្លួនមានដើម្បីទទួលបាននូវព័ត៌មានដែលបានស្នើសុំ។ អ្នកនាង Pike បានថ្លែងថា ដោយសារហេតុផលវិជ្ជាជីវៈ គាត់មិនអាចផ្តល់ដោយស្ម័គ្រចិត្តទៅមេធាវីការពារក្តីនូវខ្សែភាពយន្ត ឬសម្ភារៈវត្ថុដែលបានស្នើសុំឡើយ[15]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូង ដាច់ខាតត្រូវតែទទួលបាននូវព័ត៌មាននេះ។

១០. វិធានផ្ទៃក្នុង ទំនងជាមិនហាមឃាត់ចៅក្រមទោលម្នាក់ ដោយចេញពីគំនិតផ្តួចផ្តើមរបស់ខ្លួន គ្រាន់តែធ្វើសំណើសុំខ្សែភាពយន្ត លិខិតអនុញ្ញាតអោយចាក់ផ្សាយ និងការចូលខ្លួនរបស់អ្នកនាង Pike។ បើសិនជាតម្រូវអោយមានធ្វើតាមវិធីផ្លូវការនោះ តាមរយៈវិធាន ៤១ អង្គជំនុំជម្រះសាលាដំបូងអាចចេញដីកាដោះអោយអ្នកនាង Pike ចូលមកបង្ហាញខ្លួនបាន។ យោងទៅតាមវិធាន ៤១ "ដីកាកោះគឺជាការបង្គាប់ដល់<u>បុគ្គលណាម្នាក់</u> ឲ្យចូលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ"[16]។ តាមរយៈវិធាន ៩៣ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់អោយមានការស៊ើបអង្កេតបន្ថែម។ វិធាន ៩៣(១) ចែងថា "ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការ

---

[14] *រឿងក្តី* អៀង សារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អបជ(០១) សាលដីកាលើបណ្តឹងរបស់ជនត្រូវចោទ អៀង សារី ប្តឹងជិតចិត្តចៅក្រម Marcel Lemonde ចុះថ្ងៃទី ៩ ធ្នូ ២០០៩ ឯកសារលេខ 7, ERN: 00407716-00407724កថាខណ្ឌ ១៥។

[15] *សូមមើល* ពាក្យបណ្តឹងជិតចិត្ត ឧបសម្ព័ន្ធ គ ។ សារអ៊ីមែលរបស់អ្នកនាង Pike ទៅលោក Michael G. Karnavas ចុះថ្ងៃទី ៨ កញ្ញា ២០១០ នៅពេលដែលអ្នកនាង Pike ថ្លែងថា "ដោយសារហេតុផលវិជ្ជាជីវៈសារព័ត៌មាន យើងខ្ញុំមិនអាចផ្តល់ជូនដោយស្ម័គ្រចិត្តនូវសម្ភារៈវត្ថុដែលអ្នកកំពុងស្នើសុំឡើយ"។

[16] គូសបញ្ជាក់បន្ថែម។

ស៊ើបសួរថ្មីជាការចាំបាច់ អង្គជំនុំជម្រះសាលាដំបូង អាចបង្គាប់ឲ្យធ្វើការស៊ើបសួរបន្ថែមបាន គ្រប់ពេលវេលា ។" គ្មានពាក្យពេចន៍ណាមួយក្នុងវិធានផ្ទៃក្នុង ដែលកម្រិតនូវវិសាលភាពនៃការស៊ើបសួរ ដែលអង្គជំនុំជម្រះសាលាដំបូងអាចស្នើឡើងនោះឡើយ។

១១. វិធាន ៣៥(១)(ខ) អនុញ្ញាតអោយអង្គជំនុំជម្រះ ដាក់ទណ្ឌកម្មបុគ្គលណាដែល "បុគ្គលដែលមិនគោរពតាមសេចក្ដីបង្គាប់ឲ្យចូលរួមក្នុងដំណើរការជម្រះក្ដី ឬ មិនផ្ដល់ឯកសារ ឬ ភស្តុតាងផ្សេងទៀតឲ្យសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ។ ដូច្នេះ វិធានផ្ទៃក្នុងពិចារណាយ៉ាងច្បាស់ថា អង្គជំនុំជម្រះមានអំណាចបង្គាប់អោយបុគ្គលម្នាក់អោយចូលខ្លួន ឬ បង្ហាញឯកសារ ឬ ភស្តុតាងដទៃទៀត។ លើសពីនេះទៀត វិធាន ៣៥(២)(ខ) ចែងថា នៅពេល "អង្គជំនុំជម្រះមានហេតុផលជឿថា បុគ្គលណាម្នាក់អាចធ្លាប់ បានប្រព្រឹត្តិអំពើណាមួយ ដូចចែងក្នុងអនុវិធាន ១ ខាងលើ អង្គជំនុំជម្រះ អាច ខ- ដឹកនាំការស៊ើបសួរបន្ថែម ដើម្បីឲ្យដឹងប្រាកដថា តើមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចាត់ការតាមនីតិវិធី"។ ហេតុដូច្នេះ អំណាចរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីបំពេញកិច្ចស៊ើបសួរ មិនត្រូវបានកម្រិតត្រឹមតែការស៊ើបសួរទាក់ទងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះទេ។

១២. បើសិនជាអង្គជំនុំជម្រះសាលាដំបូង នឹងបដិសេធមិនប្រើប្រាស់នូវអំណាចដែលខ្លួនមានស្រាប់ដើម្បីបំពេញកិច្ចស៊ើបសួរដែលបានស្នើសុំ ដោយគ្រាន់តែដោយសារមេធាវីការពារក្ដី មិនមានលទ្ធភាពក្នុងទទួលបាននូវព័ត៌មានដោយខ្លួនឯង បន្ទាប់ពីបានចាត់គ្រប់វិធានការណ៍សព្វបែបយ៉ាង វានឹងរំលោភលើសិទ្ធិជាមូលដ្ឋានរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះដោយតុលាការដែលឯករាជ្យ និងឥតលំអៀង។ ជាការពិត អង្គជំនុំជម្រះសាលាដំបូង ប្រាកដជានឹងអាចយកវាធ្វើជាខែល ក្នុងចេតនាគេចវេសពីភស្តុតាងធ្ងន់ធ្ងរដែលអាចមិនគួរជាទីគាប់ចិត្ត ឬមិនផ្ដល់ផលល្អដល់នរណាម្នាក់ក្នុងសមាជិករបស់ខ្លួន។ ដោយធ្វើដូច្នេះ អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើអោយគេឃើញថា បានសមគំនិតចូលដៃជើង ឬ ជួយនិងជំរុញ ក្នុងកិច្ចប្រឹងប្រែងបិទបាំងសក្តានុពលភាពនៃភាពស្មោះត្រង់របស់តុលាការ (impropriety) ដែលបានប្រព្រឹត្តដោយសមាជិកម្នាក់របស់អង្គជំនុំជម្រះសាលាដំបូង។

១៣. វិធាន ២១(១) ចែងថា "ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្ដីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន <u>ត្រូវតែ</u>បកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និង ជនរងគ្រោះ

ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព..."[17]។ ដូចដែលបានកត់សម្គាល់ដោយ អង្គការគំនិតផ្តួចផ្តើមសង្គមសេរី (Open Society Justice Initiative) ថា ""ការប៉ុនប៉ងជ្រៀតជ្រែកក្នុងឯករាជ្យភាពរបស់តុលាការ គឺមានភាពងាយស្រួលក្នុងបិទបាំង។ វាមានតែធានាអោយមានតម្លាភាពតាមរយៈប្រព័ន្ធយុត្តិធម៌ទាំងមូលប៉ុណ្ណោះ ដែលចាប់ផ្តើមពីការតែងតាំងចៅក្រមរហូតដល់ការផ្តល់សម្អាងហេតុ ទើបសាធារណៈជនមានឱកាសដើម្បីកំណត់ថាដំណើរការប្រព្រឹត្តទៅមានភាពស្មោះត្រង់ដែរឬអត់។[18]"

១៤. ការខកខានធ្វើការស៊ើបអង្កេត ដែលជាបញ្ហាមួយដែលជះឥទ្ធិពលជាក់ស្តែងដល់សិទ្ធិជាមូលដ្ឋានរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ នឹងបង្កើតបានជាការជ្រៀងជ្រែកដល់វិស័យយុត្តធម៌ និងជាការសំពងមួយទៅលើសុចរិតភាពរបស់ដំណើរការនីតិវិធីរបស់តុលាការ។ អង្គជំនុំជម្រះសាលាដំបូងដាច់ខាតមិនត្រូវនៅតែមានចេតនាធ្វើមិនដឹងមិនលឺចំពោះបញ្ហានេះឡើយ។ ដូចដែលបានពន្យល់ដោយចៅក្រម Marchi-Uhel and Downing ថា "អង្គជំនុំជម្រះត្រូវស្ថិតនៅក្រោមកាតព្វិច្ចមួយ ដើម្បីធានាថា សុចរិតភាពនៃដំណើរការរបស់តុលាការត្រូវបានរក្សាការពារ។[19]" វាគួរជារឿងសាមញ្ញមួយសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការស្នើសុំ ឬ បង្គាប់អោយមានការស៊ើបអង្កេតដើម្បីលាតត្រដាងការពិត។ នេះគឺជាឱកាសមួយដើម្បីចង្អុលបង្ហាញថា ចៅក្រមរបស់ អវតក នឹងធ្វើសកម្មភាពដោយសំអាងទៅលើច្បាប់ និងទៅលើលក្ខខណ្ឌតម្រូវដែលថា ដំណើរការនីតិវិធីតុលាការនឹងមានភាពត្រឹមត្រូវយុត្តិធម៌ ជាជាងអោយសេចក្តីសម្រេចរបស់ខ្លួន សំអាងទៅលើភាពជាមិត្តរួមការងារជាមួយគ្នាក្នុងអង្គជំនុំជម្រះ ឬដោយសារការពិចារណាផ្សេងនៅក្រៅពីបញ្ហានេះ។

## IV. ព័ត៌មាននឹងជួយដល់អង្គជំនុំជម្រះសាលាដំបូង ក្នុងការបំពេញកិច្ចស៊ើបសួរដែលបានស្នើសុំ

[17] គូសបញ្ជាក់បន្ថែម។

[18] របាយការណ៍ស្តីពី ការជ្រៀតជ្រែកខាងនយោបាយនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (Political Interference in the Extraordinary Chambers in the Courts of Cambodia) របស់អង្គការ OPEN SOCIETY JUSTICE INITIATIVE ចេញផ្សាយខែ មិថុនា ២០១០ ទំព័រ ២៧។

[19] *រឿងក្តី* នួន ជា សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ៥១) សាលដីកាលើកទីពីរទៅលើបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស ទៅលើសំណើសុំអោយកោះហៅសាក្សី ចុះថ្ងៃទី ៩ កញ្ញា ២០១០ ឯកសារលេខ D314/2/10, ERN: 00600748-00600774 កថាខណ្ឌ ១០។

១៥. វិធាន ៤៥(១) ស្តីពី "ទម្រង់ការពាក់ព័ន្ធនឹងដីកាកោះ ដីកាបង្គាប់ឲ្យឃុំខ្លួន និង ដីកាបង្គាប់ឲ្យចាប់ខ្លួន ចែងថា៖

រាល់ដីកាកោះ ដីកាបង្គាប់ឲ្យឃុំខ្លួន និងដីកាបង្គាប់ឲ្យចាប់ខ្លួន ត្រូវមានចុះកាលបរិច្ឆេទ ហត្ថលេខា និងប្រថាប់ត្រាដោយអង្គភាពចេញដីកានោះ និង ត្រូវមានព័ត៌មានដូចខាងក្រោម:

ក-ឈ្មោះ និង ប្រសិនបើដឹង ថ្ងៃ ខែ ឆ្នាំ ទីកន្លែងកំណើត អាសយដ្ឋាន និង ព័ត៌មានដទៃទៀតដែលពាក់ព័ន្ធនឹងអត្តសញ្ញាណបុគ្គលនោះ

ខ-យោងតាមដីកា និង ការចោទប្រកាន់ដែលពាក់ព័ន្ធ

គ-អង្គភាពរបស់អង្គជំនុំជម្រះវិសាមញ្ញដែលចេញដីកា

ឃ-ទីកន្លែង ពេលវេលា និងកាលបរិច្ឆេទសវនាការ តាមករណីសមស្រប នីមួយៗ និង

ង-បញ្ជាក់ថា បុគ្គលនោះមានសិទ្ធិទទួលបាននូវជំនួយផ្នែកច្បាប់ និង សិទ្ធិត្រូវបានការពារដទៃទៀត ដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ។

១៦. ថ្ងៃខែឆ្នាំកំណើតរបស់អ្នកនាង Pike មិនត្រូវបានគេដឹង។ គាត់បានថ្លែងថា គាត់មានបំណងចង់អោយរាល់ទំនាក់ទំនងនានាមកកាន់គាត់ទាក់ទងនឹងបញ្ហានេះ ត្រូវទាក់ទងផ្ទាល់ទៅមេធាវីរបស់គាត់ គឺលោក John Keker។ លោក John Keker អាចទាក់ទងបានតាមរយៈ៖

John Keker

ការិយាល័យ Keker & Van Nest អាស័យដ្ឋានផ្ទះលេខ 710 ផ្លូវ Sansome, San Francisco, CA 94111, USA, ទូរស័ព្ទ +1 (415) 391-5400។

## V. សំណូមពរដែលមានក្នុងសំណើសុំ

**អាស្រ័យហេតុនេះ** ដោយមានហេតុផលទាំងអស់ដូចបានលើកឡើងនៅទីនេះ មេធាវីការពារក្តី សូមស្នើដល់អង្គជំនុំជម្រះសាលាដំបូង មេត្តា៖

ក. **ចេញដីកាបង្គាប់** អោយ Amanda Pike ផ្តល់មកជូនអង្គជំនុំជម្រះសាលាដំបូងនូវ៖

- ខ្សែភាពយន្តនៃការសម្ភាសន៍របស់គាត់ជាមួយចៅក្រម និល ណុន និង
- លិខិតអនុញ្ញាតអោយចាក់ផ្សាយដែលចុះហត្ថលេខាដោយចៅក្រម និល ណុន

00636149

០០២/19-09-2007-អវតក/អបជ ៦៨

~~០០២/១៣-០១-២០១១/អ.វ.ត.ក/អធសម~~

E6

ខ. ប្រសិនបើចាំបាច់ **ចេញដីកាកោះ** Amanda Pike អោយផ្តល់ភស្តុតាងពន្យល់ពីបរិបទ និង សារតានៃការធ្វើសម្ភាសន៍របស់គាត់ជាមួយចៅក្រម និល ណុន រួមមាន៖

- តើហេតុអ្វីអ្នកនាង Pike ជ្រើសរើសចៅក្រម និល ណុន ដើម្បីធ្វើការសម្ភាសន៍
- តើនៅពេលណាដែលអ្នកនាង Pike បានសម្ភាសន៍ចៅក្រម និល ណុន
- តើនៅទីណាដែលអ្នកនាង Pike បានសម្ភាសន៍ចៅក្រម និល ណុន
- តើកិច្ចសម្ភាសន៍ត្រូវធ្វើឡើងជាភាសាអ្វី និង
- ថាតើ គេមានបានជួលអ្នកបកប្រែសំណេរ ឬផ្ទាល់មាត់នៅក្នុងអំឡុងពេលសម្ភាសន៍នេះដែរឬទេ។ បើមាន តើអ្នកបកប្រែសំណេរ ឬផ្ទាល់មាត់ នោះជាអ្នកណា និង

គ. **សុំដកគុណវុឌ្ឍិ** ចៅក្រម និល ណុន អនុលោមទៅតាមវិធាន ៣៤(២)។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកពាក្យបណ្តឹងជិតចិត្តនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១៤** ខែ**មករា** ឆ្នាំ **២០១១**

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**